**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**
**សម្តេចក្រឡាហោម ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

***សម្តេចឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់***

ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មគ្រប់លំដាប់ថ្នាក់ សូមគោរពផ្ញើជូន **សម្តេច និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារទាំងអស់នូវសេចក្តីអំណរសាទរយ៉ាងក្លៀវក្លាកក់ក្តៅបំផុត ប្រកបដោយមនោសញ្ចេតនារំភើប រីករាយក្រៃលែង ក្នុងឱកាសដែលព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា **ប្រោសព្រះរាជទានគោរមងារ សម្តេចក្រឡាហោម ស ខេង** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៣៤ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៥។

គោរមងារដែល **សម្តេច** ទទួលបាននាពេលនេះ គឺពិតជាស័ក្តិសមបំផុតចំពោះវីរភាពដ៏ឧត្តុងឧត្តមថ្លៃថ្លារបស់ **សម្តេច** ដែលជាអ្នកដឹកនាំដ៏ឆ្នើមមួយរូបរបស់ប្រជាជាតិខ្មែរយើង បានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ពុះពារជំនះឧបសគ្គគ្រប់បែបយ៉ាង និងគ្រប់កាលៈទេសៈ ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ សម្រេចបាននូវសុខសន្តិភាព ឯកភាពជាតិ ស្ថិរភាពសង្គម ស្ថិរភាពនយោបាយ ពង្រឹងនីតិរដ្ឋ រក្សាការពារឯករាជ្យជាតិ បូរណភាពទឹកដី ប្រកបដោយទឹកចិត្តស្វាមីភក្តិជានិច្ចចំពោះជាតិ សាសនា ព្រះមហាក្សត្រ។

យើងខ្ញុំទាំងអស់គ្នា មានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេច** ក្រសួងមហាផ្ទៃ រួមទាំងរដ្ឋបាលរាជធានី ខេត្ត នឹងបន្តទទួលបានជោគជ័យថ្មីៗថែមទៀត សម្រេចបាននូវសមិទ្ធផលជាផ្លែផ្កាជាឧត្តមប្រយោជន៍របស់ជាតិ ស្របទៅតាមបំណងប្រាថ្នាដ៏ថ្លៃថ្លារបស់ប្រជាជនកម្ពុជា ទាំងនៅក្នុង និងក្រៅប្រទេស។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុងឧត្តមនេះ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេច** និងសូមលើកហត្ថប្រណាមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាភពផែនដី និងគុណបុណ្យព្រះត្រៃរតន៍ សូមមេត្តាប្រោសព្រំ និងប្រសិទ្ធពរជ័យជូនចំពោះ **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ទាំងអស់ សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ** សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ជ្រាលជ្រៅពីខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៥
**តំណាងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ទេសរដ្ឋមន្ត្រី**

**ចម ប្រសិទ្ធ**